# របាយការណ៍ប្រចាំខែមិថុនា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមិថុនា ឆ្នាំ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>ស្ថានភាពមន្ត្រីរាជការ</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷

- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្ត នៅថ្ងៃទី២៩/០៥/២០១៥ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី
- ចូលរួមវេទិកាសារធាណៈចំនួន ០២ ដង
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ ថ្ងៃទី០៣/៦/២០១៥ នៅខណ្ឌរដ្ឋបាលព្រៃឈើ
- ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ បន្ទប់រង់ចាំសម្រាលកូន នៅថ្ងៃទី០៤/០៦/២០១៥ នៅមណ្ឌលសុខភាពថ្មគ្រែ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសម្រេចបាន របស់គម្រោងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្ងៃទី០៤/០៦/២០១៥
- ចូលរួមប្រជុំជាមួយប្រតិភូក្រសួងបរិស្ថាន នៅថ្ងៃទី០៤/០៦/២០១៥ នៅសាលាខេត្ត
- ចូលរួមប្រជុំចរចាថ្លៃលើការងារថែទាំផ្លូវជាលក្ខណៈខួបចំនួន ១៤ គម្រោង នៅថ្ងៃទី០៥/០៦/២០១៥ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំសាមញ្ញរបស់ គ.ក.ស.ក ខេត្ត ថ្ងៃទី០៥/០៦/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំបើកសំណើដេញថ្លៃគម្រោង ចំនួន ០៤ គម្រោង សម្រាប់ឆ្នាំ២០១៥ ថ្ងៃទី០៥/០៦/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំជាមួយគណៈកម្មាធិការទី០៦ នៃព្រឹទ្ធសភា ថ្ងៃទី១០/០៦/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមកិច្ចប្រជុំពិនិត្យផ្តល់យោបល់ លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ០៥ ឆ្នាំ ២០១៥-២០១៩ ថ្ងៃទី ១១/០៦/ ២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមវាយតម្លៃប្រគល់ទទួលទំនិញ ០៤ គម្រោង សម្រាប់ឆ្នាំ២០១៥ នៅថ្ងៃទី១១/០៦/២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រារព្ធខួបលើកទី៨ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០១៥ នៅថ្ងៃទី ១២/០៦/២០១៥

- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព និងឯកសារព័ត៌មានពិន្ទុវិស័យកសាងកម្មវិធីវិនិយោគឃុំ ថ្ងៃទី១៧/០៦/២០១៥ នៅមន្ទីរផែនការ
- ចូលរួមជាគណៈអធិបតី ក្នុងពិធីសម្ពោធព្រះវិហារ និងសមិទ្ធផលក្នុងវត្តក្រចេះនៅថ្ងៃទី១៨/០៦/២០១៥ ។

3. <u>សកម្មភាពតាមការិយាល័យ</u>÷

3.1. <u>**ការិយាល័យរដ្ឋបាល និងបុគ្គលិក**</u>÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៦៥ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៤ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ១៨ លេខ
- លិខិតក្រសួងនានា ចំនួន ០៤ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣៩ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៣២ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ១៦ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ១៦ លេខ

គ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុប ចំនួន ២១ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី**ឯកឧត្តមអភិបាលខេត្ត** ចំនួន ០១លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ២០ លេខ

ឃ. <u>ផ្នែកបញ្ជីវត្តមាន</u>÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. <u>**ការិយាល័យផ្លូវជនបទ**</u>÷

<u>**សកម្មភាពការងារ**</u>

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវព្រែកគ្រៀង-អាជេន ប្រវែង ៣៧,៣០ គ.ម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ សោបក្រោម-ជ្រោយអំពិល ប្រវែង ៤១,៨០០ ម៉ែត្រ ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ឃុំកំពង់គរ ឃុំតាម៉ៅ ឃុំចិបក់ ស្រុកព្រែកប្រសព្វ
- ប្រធានមន្ទីរ និងក្រុមការងារផ្លូវជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត គណៈកម្មាធិការលទ្ធកម្មខេត្ត និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យការងារវាយតម្លៃបញ្ចប់សុពលភាពផ្លូវ ឈើ-ស្រែទ្រៀក ប្រវែង ១៩,២០០ ម៉ែត្រ ជូនក្រុមហ៊ុន ស្ថិតនៅឃុំឆ្លូង ឃុំដីរីផុង ស្រុកឆ្លូង
- ប្រធានមន្ទីរ និងជាប្រធាន PIU និងក្រុមការងារខេត្ត RIP-III អង្គភាពគ្រប់គ្រង PMU -RIP -III និងក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះពិនិត្យការងារ និងវាយតម្លៃប្រគល់-ទទួល ជួសជុលផ្លូវថែទាំជាលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩,៦០ គម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ និងជួសជុលផ្លូវថែទាំជាលក្ខណៈខួប សោប-ស្រែធៀត ប្រវែង ១១,៧០ គម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ

- ប្រធានមន្ទីរ និងក្រុមការងារការិយាល័យផ្លូវជនបទ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះពិនិត្យការងារជួសជុលស្ពានឈើ ១ កន្លែង ប្រវែង ៣០ ម៉ែត្រ រអិលស្រុតសសរគ្រឹះ ស្ថិតនៅភូមិកោះខ្មែរ ឃុំអូរគ្រៀង ស្រុកសំបូរ
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦.៣០០ ម៉ែត្រ ស្ថិតនៅឃុំដីរីផុង ស្រុកឆ្លូង និង ផ្លូវរលៀក-ប្រម៉ា ប្រវែង ១០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង ។

**<u>លទ្ធផលការងារ</u>**

- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦ ៣០០ ម៉ែត្រ ស្ថិតនៅឃុំដីរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៦០ %
- ចុះពិនិត្យការងារជួសជុលស្ពានឈើ ១ កន្លែង ប្រវែង ៣០ ម៉ែត្រ រអិលស្រុតសសរគ្រឹះ ស្ថិតនៅភូមិកោះខ្មែរ លទ្ធផលសម្រេចបាន ១០០ %
- ប្រធានមន្ទីរ និងជាប្រធាន PIU និងក្រុមការងារខេត្ត RIP-III អង្គភាពគ្រប់គ្រង PMU -RIP -III និងក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះពិនិត្យការងារនិងវាយតម្លៃប្រគល់-ទទួល ជួសជុលផ្លូវថែទាំជាលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩,៦០ គម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ និងជួសជុលផ្លូវថែទាំជាលក្ខណៈខួប សោប-ស្រែងៀត ប្រវែង ១១,៧០ គ.ម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០០ % ។

3.3. **<u>ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷</u>**

- ចុះប្រមូលទិន្នន័យ និងធ្វើបច្ចុប្បភាពអណ្តូងស្នប់ ៥៨ អណ្តូង ឃុំស្វាយជ្រះ ស្រុកស្នួល និង ២២ អណ្តូង ឃុំកំពង់ដំរី ស្រុកឆ្លូង
- ចុះត្រួតពិនិត្យ និងវាយតំលៃអណ្តូងស្នប់របស់អង្គការ PADEK កំពុងសាងសង់នៅឃុំដីរីផុង បានចំនួន ០៣ អណ្តូង ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷</u>** (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍÷</u>**

- ចុះបង្កើត គ.អ.ភ នៅភូមិសម្បទានកាកុត ក្នុងឃុំសំបុក ស្រុកចិត្របុរី ដែលមានចំនួនសរុប ១១នាក់ ក្នុងនោះស្ត្រីមាន ០៧ នាក់ ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច÷</u>** (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ÷</u>**

- ចុះផ្សព្វផ្សាយ និងបំផុសប្រជាជនឲ្យយល់ដឹងអំពីអនាម័យ ហើយស្ម័គ្រចិត្តសាងសង់បង្គន់ ដោយខ្លួនឯងបានចំនួន ៧៧ បង្គន់:

ស្រុកសំបូរ÷ ឃុំសណ្ដាន់ ០៤ បង្គន់ និងឃុំកោះខ្ញែរ ១១ បង្គន់

ស្រុកឆ្លូង÷ ឃុំព្រែកសាម៉ាន់ ២៩ បង្គន់ និងឃុំថ្មី ២១ បង្គន់

ព្រែកប្រសព្វ÷ ឃុំចំបក់ ០៦ បង្គន់

ចិត្របុរី÷ ឃុំសំបុក ០៦ បង្គន់ ។

- យុទ្ធនាការផ្សព្វផ្សាយអនាម័យតាមសាលា ស្ដីពីការលាងសម្អាតដៃ និងរបៀបប្រើប្រាស់បង្គន់:
  - សាលាបឋមសិក្សាប្រហ្លូត ឃុំដំរីផុង មានសិស្សចូលរួម ១៥៣ នាក់ ស្រី៩៨ នាក់
  - សាលាបឋមសិក្សាមានដំរីផុង ឃុំដំរីផុង សិស្សចូលរួម ២៩៩ នាក់ ស្រី ១៤៩ នាក់
  - សាលាបឋមសិក្សាព្រៃគោ ឃុំដំរីផុង មានសិស្សចូលរួម ២៩៨ នាក់ ស្រី ១៦២ នាក់
  - សាលាបឋមសិក្សាបឹងកៀប ឃុំដំរីផុង មានសិស្សចូលរួម ១៤៣ នាក់ ស្រី ៨៦ នាក់
  - សាលាបឋមសិក្សាវាលកន្សែង ឃុំដំរីផុង សិស្សចូលរួម ២៦០ នាក់ ស្រី ១៧៥ នាក់
  - សាលាបឋមសិក្សាប្រម៉ា ឃុំដំរីផុង មានសិស្ស ចូលរួម ២២០ នាក់ ស្រី ១៣៩ នាក់
  - សាលាបឋមសិក្សាព្រែកសំរោង ឃុំខ្សាច់អណ្ដែត សិស្សចូលរួម ២៨៨ នាក់ ស្រី ១៣២ នាក់
  - សាលាបឋមសិក្សាភូមិថ្មី ឃុំខ្សាច់អណ្ដែត សិស្សចូលរួម ២៦១ នាក់ស្រី ១៥៣ នាក់
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពី ការកសាងផែនការសកម្មភាពជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ ២០១៤-២០១៥ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានអ្នកចូលរួម ៤៨ នាក់ ស្ត្រី ០៨ នាក់
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៣ ស្ដីពីការបន្សុំផែនការសកម្មភាពជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១៤-២០១៨ នៅសណ្ឋាគារ អង្គរសិនធីរី ក្រុងសៀមរាប មានអ្នកចូលរួម ៥២ នាក់ ស្ត្រី ០៨ នាក់ ។

3.8. **ការងារបណ្ដុះបណ្ដាលមន្ត្រីរាជការ÷**

លោក លឹម ជាវហាវ ប្រធានមន្ទីរ និងមន្ត្រីក្រោមឱវាទ ចំនួន ១៤ នាក់ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពី ការកសាងផែនការសកម្មភាពសម្រាប់ថ្នាក់រាជធានី-ខេត្ត ស្ដីពីការផ្គត់ផ្គង់ទឹក និងលើកកម្ពស់អនាម័យជនបទ ឆ្នាំ ២០១៤ -២០១៨ ចាប់ពីថ្ងៃទី ០២ - ០៣ ខែ មិថុនា ឆ្នាំ ២០១៥ នៅមន្ទីរអភិវឌ្ឍន៍ជនបទ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។

4. **ទិសដៅបន្ត÷**

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ស្រុកព្រែកប្រសព្វ ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ
- ចុះជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦.៣០០ ម៉ែត្រ ឃុំដំរីផុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០.៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង

- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវសំរ៉ង-ចឹង ប្រវែង ៨.០០ គម ស្ថិតនៅឃុំរមៀម ស្រុកស្នួល និងផ្លូវក្បាលស្នួល-ស្នួលលិច ប្រវែង ៤,០០ គម ឃុំស្នួល ស្រុកស្នួល
- បន្តចុះពិនិត្យការងារជួសជុលអណ្តូង នៅស្រុកចិត្របុរី និងស្រុកស្នួល
- បង្កើត គ.អ.ភ នៅភូមិចំនួន ០១ គឺ ភូមិសម្បទានកាំពី ដែលស្ថិតក្នុងឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ
- បន្តចុះផ្សព្វផ្សាយ និងបំផុសប្រជាជនឲ្យយល់ដឹងអំពីអនាម័យ ហើយស្ម័គ្រចិត្តសាងសង់បង្គន់ ដោយខ្លួនឯង នៅស្រុកចិត្របុរី ស្រុកឆ្លូង ស្រុកព្រែកប្រសព្វ ស្រុកសំបូរ
- បន្តចុះអប់រំផ្សព្វផ្សាយ ស្តីពី ការលើកកម្ពស់អនាម័យនៅតាមសហគមន៍ និងសាលារៀន នៅស្រុកឆ្លូង និងស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**